# គម្រោងអាជីវកម្មដំណាំត្រសក់ផ្អែម ក្នុងផ្ទះសំណាញ់

# MUSK MELON CULTIVATION IN NET HOUSE



រៀបចំដោយ

**គណៈកម្មការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃ**

**ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (អេ.អ.ឌី.ប៊ី)**

ខែតុលា ឆ្នាំ២០២៣

# មាតិកា


១-សេចក្តីផ្តើម ........ ១

២-ការអនុវត្តការដាំដុះ ........ ១

២.១ ការជ្រើសរើសពូជ ........ ១

២.២ រដូវកាលដាំដុះ ........ ១

២.៣ ការរៀបចំដី ........ ១

២.៤ ការរៀបចំប្រព័ន្ធស្រោចស្រពដំណក់ទឹក និងការគ្របរង ........ ២

២.៥ ការដាំកូន ........ ២

២.៦ ការរៀបចំចំណារ និងទ្រើង ........ ៣

២.៧ ការថែទាំ ........ ៣

ក. ការតាក់តែងមែក ........ ៣

ខ. ការជ្រើសរើសផ្លែ ........ ៣

គ. ការចងផ្លែ ........ ៤

ឃ. ការដាក់ជី ........ ៤

២.៨ ការគ្រប់គ្រងសត្វល្អិត និងជំងឺ ........ ៤

ក. សត្វល្អិត វិធានការការពារ កម្ចាត់ ........ ៤

ខ. ជំងឺ និងវិធានការការពារ ព្យាបាល ........ ៥

២.៩.អាយុកាលដាំដុះ និងការប្រមូលផល ........ ៨

៣-តម្រូវការទុនដំបូងក្នុងការដាំដុះដំណាំត្រសក់ផ្អែម ក្នុងផ្ទះសំណាញ់ ២៥០ ម៉ែត្រការ៉េ ........ ៨

៤-ការវិភាគសេដ្ឋកិច្ចលើការដាំដុះដំណាំត្រសក់ផ្អែម ក្នុងផ្ទះសំណាញ់ ២៥០ ម៉ែត្រការ៉េ ........ ៩

៥-លទ្ធភាពចំណេញផ្អែកលើបម្រែបម្រួលទិន្នផល ........ ១០

៦-ខ្សែច្រវាក់តម្លៃ ........ ១០

៧-ហានិភ័យ ........ ១១

៨-សេចក្តីសន្និដ្ឋាន ........ ១១

## ១-សេចក្តីផ្តើម

ត្រសក់ផ្អែមជាដំណាំថ្មីមួយប្រភេទដែលទើបនាំចូលគ្រាប់ពូជមកដាំដុះនៅកម្ពុជា។ បច្ចេកទេសដាំដុះ ថែទាំប្រភេទដំណាំមួយនេះគឺនៅមានកម្រិតនៅឡើយ។ កសិករនៅតំបន់មួយចំនួនបានចាប់ផ្តើមដាំដុះត្រសក់ផ្អែម ពីព្រោះមានតម្រូវការទីផ្សារ និងមានតម្លៃថ្លៃសមរម្យ។ ការពិពណ៌នាជាច្រើនបានបង្ហាញថា ផ្លែត្រសក់ផ្អែមមានរសជាតិឆ្ងាញ់ (ត្រសក់ទុំ) មានអាហារូបត្ថម្ភសម្បូរបែប ថែមទាំងផ្តល់នូវអត្ថប្រយោជន៍ជាច្រើនសម្រាប់សុខភាពដល់អ្នកបរិភោគទៀតផង។

## ២-ការអនុវត្តការដាំដុះ

**២.១.ការជ្រើសរើសពូជ÷** ត្រសក់ផ្អែម មានពូជច្រើនប្រភេទដែលនាំចូល ហើយពុំអាចទុកពូជបន្តបានទេ (ពូជកូនកាត់/Hybrid-F1)។ ពូជដែលមានរសជាតិឆ្ងាញ់ និងពេញនិយមនៅលើទីផ្សារកម្ពុជានាពេលបច្ចុប្បន្ន គឺពូជត្រសក់ផ្អែមសំណាញ់ខៀវ (Green net melon)។




**២.២.រដូវកាលដាំដុះ÷** ត្រសក់ផ្អែមអាចដាំបានគ្រប់រដូវកាលដោយដាំដុះក្នុងផ្ទះសំណាញ់។ រីឯនៅលើទីវាលកសិករអាចដាំដុះបានចាប់ពីខែវិច្ឆិកា ដល់ខែកុម្ភៈ ដោយរំពឹងការប្រមូលផលនៅអំឡុងខែមករា ដល់ខែមេសា។ ត្រសក់ផ្អែម ជាដំណាំដែលត្រូវការពន្លឺថ្ងៃ ហើយងាយរងការបំផ្លាញពីជំងឺ សត្វល្អិត និងដីជាំទឹក។

**២.៣.ការរៀបចំដី÷** គឺជាដំណាក់កាលសំខាន់សម្រាប់ដំណាំត្រសក់ផ្អែម។ ការរៀបចំដីបានល្អធ្វើឱ្យកូនត្រសក់មានសុខភាពល្អ មិនងាយរងនូវជំងឺនានា ជាពិសេសជំងឺលើឫសដំណាំ។ កសិករត្រូវភ្ជួរដីឱ្យម៉ដ្ឋល្អពី ២-៣សារ និងហាលដីរយៈពេលពី ១០-១៥ថ្ងៃ។ ក្រោយពីហាលដីរួចត្រូវយកជីកំប៉ុស្តិ៍គោកចំនួន ០.៥គ.ក/ម៉ែ$^{២}$ ប្រើជីទ្រាប់បាត ២០-២០-១៥+TE ចំនួន ១៦ក្រាម/ម៉ែ$^{២}$ ទៅបាចហើយរាស់លុប ទើប



លើកជារងដោយប្រើគម្លាតពីពាក់កណ្ដាលរងមួយទៅពាក់កណ្ដាលរងមួយ ១.៣-១.៥ម៉ែត្រ ទទឹងរង ០.៨ ម៉ែត្រ និងកម្ពស់រងពី ០.២០-០.៣០ម៉ែត្រ។

**២.៤. ការរៀបចំប្រព័ន្ធស្រោចស្រពដំណក់ទឹក និងការគ្របរង៖** ការប្រើប្រាស់ប្រព័ន្ធដំណក់ទឹកដើម្បីកាត់បន្ថយកម្លាំងពលកម្ម និងគ្រប់គ្រងទឹកបានល្អតាមតម្រូវការលូតលាស់របស់ដំណាំត្រសក់ផ្អែម។ កសិករត្រូវដាក់ទុយោដំណក់ទឹកលើរង ដោយដាក់ផ្នែកដែលមានរន្ធមកខាងលើ។ បន្ទាប់មកកសិករអាចគ្របរងដោយចំបើង ឬស្លឹករុក្ខជាតិស្ងួត ឬកៅស៊ូគ្របរង ដើម្បីជួយរក្សាសំណើមដី ការហូរច្រោះរង និងការពារស្មៅដុះ។ កសិករត្រូវប្រើកៅស៊ូគ្របរងដោយយកផ្នែកខ្មៅផ្កាប់ចុះក្រោម និងយកបន្ទះឬស្សីតូចៗដោតភ្ជាប់នឹងដីឬកាយដីកប់លុបជើងថង់ប្លាស្ទិកគម្របរង។ កសិករត្រូវគ្របរងយ៉ាងតិច ៧ថ្ងៃមុនដាំកូនដំណាំ ដើម្បីឱ្យងាប់ស្មៅ និងកម្ចាត់សត្វល្អិតដែលមាននៅក្នុងដីនៃរងដំណាំ។




**២.៥. ការដាំកូន៖** ដំបូងត្រូវយកគ្រាប់ពូជមកបណ្ដុះក្នុងថាសបណ្ដុះរយៈពេល ៩-១២ ថ្ងៃ ទើបដកមកដាំក្នុងរងដំណាំដែលបានរៀបចំរួចរាល់។ បីថ្ងៃមុនដាំដុះត្រូវស្រោចស្រពលើរងឱ្យជោកផ្អែតទឹកដោយលាយជាមួយថ្នាំកម្ចាត់ជំងឺផ្សិត មេតាឡាក់ស៊ីល (Metalaxyl) ដើម្បីការពារជំងឺផ្សិត។

ពេលវេលាដាំកូនដំណាំដែលល្អបំផុត គឺនៅពេលរសៀល (ចាប់ពីម៉ោង ៣ល្ងាចទៅ) ដោយមានចន្លោះគុម្ពពី ៦០-៧០ស.ម ពីរជួរក្នុងមួយរង (ដាំម៉ុំចង្ក្រាន) ដើម្បីឱ្យត្រសក់ផ្អែមអាចស្រូបជីជាតិ និងលូតលាស់បានល្អ។ ទំហំដី ២៥០ម៉$^{២}$ ត្រូវដាំកូនដំណាំត្រសក់ផ្អែមចំនួន៥០០ដើម ដោយបូកបន្ថែមការបាត់បង់ ១០% ដូច្នេះកសិករត្រូវការកូនដំណាំសរុបចំនួន ៥៥០ដើម។





**២.៦. ការរៀបចំចំណារ និងទ្រើង÷** គួរធ្វើឡើងភ្លាមបន្ទាប់ពីដាំកូនដំណាំរួច ដើម្បីកុំឱ្យប៉ះពាល់ដល់សុខភាពកូនត្រសក់។ ចំណារទ្រើងធ្វើពីបង្គោលឈើ ឬឫស្សីដោយដោតជាជួរ និងប្រើខ្សែនីឡុងចងជាទ្រើង សម្រាប់ដើមត្រសក់ផ្អែមតោងរុំឡើង។



**២.៧. ការថែទាំ÷** ត្រូវស្រោចទឹកក្នុងមួយថ្ងៃ២ដង គឺនៅពេលព្រឹក និងពេលរសៀលផ្អែកលើសំណើមដីដោយប្រើប្រាស់ប្រព័ន្ធដំណក់ទឹក(មិនត្រូវការទឹកជោគជាំនោះទេ)។ ដំណាំត្រសក់ផ្អែមជាដំណាំងាយជួបបញ្ហាជំងឺ និងសត្វល្អិត ដែលត្រូវការពារថែទាំច្រើន។

**ក. ការតាក់តែងមែក÷** ត្រសក់ផ្អែមក្នុងមួយដើមតម្រូវទុកតែមួយផ្លែ ដូចនេះការតាក់តែងមែក និងធ្វើខ្នែងជាការងារសំខាន់សម្រាប់ជោគជ័យក្នុងផលិតកម្មផងដែរ។ ក្រោយដាំបាន១២ថ្ងៃ កសិករចាប់ផ្តើមកាត់ពីខ្នែងទី១ ដល់ខ្នែងទី៨ ត្រូវរក្សាខ្នែងទី ៩ដល់ទី១២ សម្រាប់ជ្រើសរើសផ្លែ ហើយខ្នែងបន្ទាប់ត្រូវកាត់ចេញរហូតដល់ខ្នែងចុងក្រោយ។ បន្ទាប់មកត្រូវកាត់ត្រួយនៅពេលមានស្លឹកចាប់ពីទី២១-២៥ អាស្រ័យលើសុខភាពដំណាំ ដែលអាចមានកម្ពស់ដើមពី ១.៦-១.៨ម៉ែត្រ។

**ខ. ការជ្រើសរើសផ្លែ÷** ធ្វើឡើងពីពេលដំណាំត្រសក់មានអាយុចាប់ពី ៣០-៣៥ថ្ងៃ។ ផ្កាញីដែលចេញនៅខ្នែងទី៩-១២ត្រូវរក្សាទុកឱ្យបង្កកំណើតកាន់ជាក្តិប។ ក្តិបដែលកាន់មានពណ៌បៃតងស្រស់ ឯផ្កាខាងចុងក្តិបប្រែពណ៌ហើយក្រៀម។ ក្នុង១ដើមត្រូវរក្សាទុកក្តិបយ៉ាងតិច៣ រហូតដល់ទំហំដែលអាចពិនិត្យឃើញថា ជាក្តិបល្អ មានរាងទ្រវែងបន្តិច គ្មានជំងឺ មិនមានស្នាមប្រេះ ឆ្នូត និងសត្វទិចឬបំផ្លាញ។ ក្រោយមកត្រូវរក្សាក្តិបតែ១ដែលល្អ ដោយកាត់ក្តិបផ្សេងៗនិងខ្នែងលាស់ថ្មីចេញពីដើម ដើម្បីទុកសារធាតុ



ចិញ្ចឹមផ្លែឱ្យលូតលាស់ធំល្អ។ បន្ទាប់ដែលត្រសក់ឱ្យតោងខ្សែទ្រើង នៅពេលដើមត្រសក់ចេញផុតស្លឹកទី២៣ ឬ២៥ ត្រូវកាត់ចេញ ឬក្រៀវចុងត្រសក់ចោលដើម្បីឱ្យដើមត្រសក់មានធាតុចិញ្ចឹម និងមានកម្លាំងគ្រប់គ្រាន់សម្រាប់បំប៉នផ្លែរហូតដល់ទុំ។

**គ. ការចងផ្លែ÷** បន្ទាប់ពីសម្រេចទុកផ្លែចុងក្រោយហើយ ក្តិបដទៃត្រូវកាត់ចេញ។ ចំពោះផ្លែដែលរក្សាទុកត្រូវចងព្យួរបន្តោងនឹងខ្សែទ្រើងដើម្បីជួយទប់ផ្លែ ការពារផ្លែកុំឱ្យប៉ះកៅស៊ូគ្របរងដែលអាចធ្វើឱ្យផ្លែរលួយ មានស្នាម ឬក្រិនផ្នែកខាងក្រោមនៃផ្លែ។




**ឃ. ការដាក់ជី÷** នៅដំណាក់កាលដំបូងគប្បីប្រើប្រាស់ជីដែលជំរុញដល់ការលូតលាស់ឫស និងដើម (អាសូត និងផូស្វ័រ)។ នៅពេលដំណាំជិតចេញផ្កាត្រូវបង្កើនជីជំរុញផ្កា ផ្លែ (ប៉ូតាស្យូម កាល់ស្យូម និងម៉ាញ៉េស្យូម) និងជីសារធាតុចិញ្ចឹមផ្សេងទៀត ដើម្បីបង្កើនទិន្នផល។




**២.៨. ការគ្រប់គ្រងសត្វល្អិត និងជំងឺ÷** ជាទូទៅដំណាំត្រសក់ផ្អែមតែងជួបប្រទះជំងឺ និងការបំផ្លាញពីសត្វល្អិតចង្រៃផ្សេងៗដែលអាចមានផលប៉ះពាល់អាក្រក់ដល់ផ្លែត្រសក់។ ការថែទាំ និងការតាមដានពិនិត្យមើលដំណាំត្រសក់ផ្អែមជាប្រចាំគឺជាការងារចាំបាច់បំផុត។

**ក. សត្វល្អិត វិធានការការពារ កម្ចាត់÷**

សត្វល្អិតដែលតែងជួបប្រទះលើដំណាំត្រសក់ផ្អែមមានដូចជា÷

-អណ្តើកមាស ពីងពាងក្រហម រុយស រុយទិចផ្លែ ស្រឹង បំផ្លាញពីដំណាក់កាលកូនដំណាំ រហូតដល់ដំណាក់កាលផ្លែ។

-ដង្កូវស៊ីញៀ ដង្កូវស៊ីត្រួយ ដង្កូវមេអំបៅ ដង្កូវមូរស្លឹក...ជាដើម។ ពួកវាស៊ីបំផ្លាញត្រួយ និងស្លឹក ចាប់ពីដំណាក់កាលកូនរហូតដល់ដំណាក់កាលមានផ្លែ ។

-សត្វល្អិត ទ្រីប ចៃ ជញ្ជក់រុក្ខរស ស្លឹកត្រួយខ្ចី ផ្កា ហើយបង្ករោគ និងចម្លងជំងឺវីរុស (ស្លឹករួញ ក្រិន) ធ្វើឱ្យដើម និងស្លឹកត្រសក់ក្រិនរួញក្រញាញ់ ហើយជួនកាលប្រេះក្លិប ឬផ្លែខ្ចី។ ចំពោះផ្លែត្រសក់នៅជាប់ដើមដែលមានជំងឺ មើលពីខាងក្រៅមានលក្ខណៈធម្មតា ប៉ុន្តែគុណភាពត្រូវបាត់បង់ (ទុំមុនអាយុ រសជាតិសាប ឬមិនសូវផ្អែម សាច់ទន់មិនស្រួយ គ្មានក្រឡាសំណាញ់... )។




-ត្រូវមានការប្រុងប្រយ័ត្នក្នុងការបិទ-បើកទ្វារចេញចូល និងជម្រះស្មៅនៅជុំវិញផ្ទះសំណាញ់ដែលជាជម្រកសត្វល្អិតចង្រៃ។

-ដាក់អន្ទាក់ចាប់សត្វល្អិត ទ្រីប ដោយប្រើផ្ទាំងក្រដាសអន្ទាក់ស្អិត

-ប្រើប្រាស់ថ្នាំកសិកម្មកម្ចាត់សត្វបំផ្លាញលើដំណាំមានដូចជា÷

- អាបាមិចទីន (Abamectin) កម្ចាត់ពីងពាងក្រហម
- ស្ពីណឺតូរ៉ាម បូកជាមួយ មេថូស៊ីហ្វេនណូសាយ (Spinetoram + Methoxyfenozide) កម្ចាត់ដង្កូវរយ ដង្កូវស៊ីត្រួយ និងដង្កូវស៊ីញៀ។
- អ៊ីមមីដាក្លព្រីដ (Imidacloprid) កម្ចាត់ចៃ ទ្រីប រុយស ស្រឹង និងដង្កូវស៊ីញៀ។
- ភីមេត្រូស៊ីន (Pymetrozine) កម្ចាត់ចៃ
- អេម៉ាមិចទិន ប៊ិនសូអាត (Emamectin Benzoate) កម្ចាត់ទ្រីប ដង្កូវស៊ីត្រួយ និងដង្កូវរយ។
- ក្លរ៉ង់ត្រានីលីប្រូល (Chlorantraniliprole) កម្ចាត់ដង្កូវរយ

**ខ. ជំងឺ និងវិធានការការពារ ព្យាបាល÷** ត្រសក់ផ្អែមតែងជួបប្រទះជំងឺមួយចំនួនដូចខាងក្រោម÷

**ជំងឺអង់ត្រាក់ណូស (Anthracnose)**÷ រោគសញ្ញាសំខាន់ៗរបស់វារួមមាន÷ ស្លឹកចាប់ផ្តើមលេចចេញស្នាមអុជមូលៗហើយប្រែជាពណ៌លឿង។ នៅលើផ្លែមានស្នាមអុជមូល ក្រៀមផតចូលក្នុងសាច់ផ្លែ។ នៅលើដើមមានស្នាមជាំឬដំបៅ ហើយធ្វើឱ្យដើម និងស្លឹកស្រពោន។



**ជំងឺ Downy Mildew និងជំងឺ Powdery Mildew÷** បង្កឡើងដោយពពួកផ្សិតដែលកសិករច្រើនតែជួបប្រទះនៅដំណាក់កាលផ្លែ។ កើតមាននៅលើស្លឹកត្រសក់ ដែលប្រែពណ៌ពីបៃតងចាស់ទៅលឿងទុំយ៉ាងឆាប់រហ័ស និងផ្នែកខាងក្រោមនៃស្លឹកមានចេញជាម្សៅ។




**ជំងឺរលាកគល់កូនដំណាំ** (Damping Off)÷ កូនដំណាំតូចៗ ដួលទាំងនៅស្រស់ ដោយនៅផ្នែកគល់មានពណ៌ត្នោត ឬខ្មៅហើយរលួយ ដែលងាយឆ្លងពីដើមមួយទៅដើមមួយ។



**ជំងឺរលាកចេញជ័រ** (Gummy Stem Blight)÷



**ជំងឺហ្វូហ្សារីយ៉ូមស្រពោន** (Fusarium Rot, Fusarium Wilt)÷ គឺជាជំងឺផ្សិតប៉ះពាល់ដល់ជាលិការុក្ខជាតិដែលបណ្តាលឱ្យឫសដំណាំរលួយ មិនលូតលាស់ ស្លឹកនិងផ្លែដំណាំប្រែជាស្រពោន និងងាប់។



**ជំងឺរលាកដើមក្លែរ៉ូទីញ្ញូមរូលស៊ី** (Southern Blight/White Mold)÷



**ជំងឺបាក់តេរីរលួយស្អុយផ្លែ** (Bacterial Fruit Blotch) ÷



**ជំងឺបាក់តេរីរទុះស្លឹក** (Angular Leaf Spot)÷



***វិធានការពារ និងព្យាបាល***÷

- លាយល្បាយដីបណ្តុះកូនឱ្យបានល្អ ដោយលីងឬចំហុយដីសម្លាប់មេរោគផ្សិត
- ប្រើប្រាស់ពូជធន់នឹងជំងឺនេះ
- ជ្រើសរើសទីតាំងដែលមានចរន្តខ្យល់បក់ល្អ និងជៀសវាងម្លប់ដើមឈើធំៗ

- ជៀសវាងដាច់ខាតការស្រោចទឹក តាមវិធីបាញ់ពីលើស្លឹក សំណើមច្រើន
- ជៀសវាងការស្រោចទឹកនៅពេលព្រលឹមពេក នៅពេលដែលស្លឹកមានសំណើមដោយទឹកសន្សើម និងនៅពេលល្ងាចពេក នៅពេលដែលស្លឹកមិនមានលទ្ធភាពក្នុងការសម្ងួតផ្ទៃរបស់វាមុនពេលមានសំណើម
- រក្សាបរិមាណជីជាតិអាសូតក្នុងកម្រិតសមស្របត្រូវការរបស់ដំណាំ
- ប្រើថ្នាំកសិកម្មការពារឬព្យាបាល មានដូចជា÷ មេតាឡាក់ស៊ីល (Metalaxyl) ខប់ពើ អ៊ុកស៊ីក្លរីដ (Copper Oxychloride) ខប់ពើ ហ៊ីដ្រុកស៊ីដ (Copper Hydroxide) ឌីហ្វិណូកូណាហ្សូល (Difenoconazole) អាហ្សូស៊ីស្ត្រូប៊ីន (Azoxystrobin) ឬធីរ៉ាម (Thiram) ។

**២.៩.អាយុកាលដាំដុះ និងការប្រមូលផល÷**

-អាយុកាលបណ្តុះកូនត្រូវប្រើប្រាស់រយៈពេលពី ៩ ដល់ ១២ថ្ងៃ

-ដាំពី ១-២ជួរក្នុងមួយរងដំណាំ

-ចន្លោះគុម្ព ៦០-៧០ស.ម

-ដាំ៣វដ្តក្នុងមួយឆ្នាំ

-រយៈពេលដាំដុះ ៦៥-៧៥ថ្ងៃ/វដ្ត

ត្រសក់ផ្អែមជាដំណាំដែលមិនប្រកាន់រដូវដាំដុះ ប៉ុន្តែជាដំណាំមិនត្រូវការទឹកភ្លៀង និងការស្រោចស្រពទឹកជោគជាំនោះទេ។ ជាទូទៅ ដំណាំត្រសក់ផ្អែមអាចប្រមូលផលបាននៅអាយុ ៦៥-៧៥ថ្ងៃក្រោយការដាំ(អាស្រ័យលើពូជ)។ ដើម្បីឱ្យត្រសក់មានរសជាតិផ្អែមល្អ គួរផ្តាច់ទឹក ឬឈប់ស្រោចទឹកមុនពេលប្រមូលផលយ៉ាងតិច៣ថ្ងៃ បើផ្តាច់ទឹកយូរពេកអាចធ្វើឱ្យដើមស្វិត និងប៉ះពាល់ដល់រសជាតិត្រសក់។ ត្រសក់ផ្អែមអាចរក្សាផ្លែបានពី ៣-៥ថ្ងៃ នៅទីត្រជាក់ ក្នុងកេស ឬទូទឹកកក ដែលធ្វើឱ្យផ្លែត្រសក់កាន់តែមានរសជាតិផ្អែម និងក្រអូប។

**៣-តម្រូវការទុនដំបូងក្នុងការដាំដុះដំណាំត្រសក់ផ្អែម** ក្នុងផ្ទះសំណាញ់ ២៥០ ម៉ែត្រការ៉េ

| **បរិយាយ** | **ចំនួនទឹកប្រាក់ (រៀល)** |
|---|---|
| ចំណាយលើការដាំដុះ-ថែទាំ | 1,009,000 |
| ចំណាយលើប្រព័ន្ធស្រោចស្រព និងសម្ភារៈផ្សេងៗ | 12,454,000 |
| **សរុប** | 13,463,000 |

**៤-ការវិភាគសេដ្ឋកិច្ចលើការដាំដុះដំណាំត្រសក់ផ្អែម** ក្នុងផ្ទះសំណាញ់ ២៥០ ម៉ែត្រការ៉េ

-បទពិសោធន៍÷ ការដាំដុះរបស់កសិករនៅស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង

-ទិន្នផលទទួលបានពី ៦៥%-៨៥% ឬពី ៥៥៣-៧២៣គីឡូក្រាមនៃ៥០០ដើម (ជាមធ្យមមួយផ្លែមានទម្ងន់ ១.៧ គីឡូក្រាម)

-តម្លៃកំណត់ក្នុងកុងត្រា÷ ៦ ០០០ រៀល/គ.ក

| **បរិយាយ** | **ឯកត្តា** | **ចំនួន** | **តម្លៃ/ឯកត្តា** | **ទឹកប្រាក់** | **ចំនួនសារ** | **ទឹកប្រាក់សរុប** |
|---|---|---|---|---|---|---|
| **១-ចំណូលពីការលក់** | គ.ក | 638 | 6,000 | 3,828,000 | | **3,828,000** |
| **២-ចំណាយសរុប = ចំណាយប្រែប្រួល + ចំណាយមិនប្រែប្រួល** | | | | | | **1,892,389** |
| **២.ក-ចំណាយប្រែប្រួលសរុប** | | | | | | **1,009,000** |
| ការរៀបចំដី (ភ្ជួរ និងលើករង) | វគ្គ | 1 | 80,000 | 80,000 | | 80,000 |
| ពូជ | កញ្ចប់ | 2 | 16,000 | 32,000 | | 32,000 |
| ជីកំប៉ុស្តិ៍ កំបោរស | វគ្គ | 1 | 150,000 | 150,000 | | 150,000 |
| ជីគីមី (N-P-K-Ca-Mg) | គ.ក | 20 | 4,100 | 82,000 | | 82,000 |
| ថ្នាំគីមី (សត្វល្អិត ជំងឺ និងជីបំប៉ន) | វគ្គ | 1 | 100,000 | 100,000 | | 100,000 |
| ប្រេងឥន្ធនៈ(សាំង/ម៉ាស៊ូត) | លីត្រ | 35 | 5,000 | 175,000 | | 175,000 |
| កម្លាំងពលកម្ម | វគ្គ | 1 | 270,000 | 270,000 | | 270,000 |
| ការប្រមូលផល/វេចខ្ចប់ | វគ្គ | 1 | 120,000 | 120,000 | | 120,000 |
| **២.ខ-ចំណាយមិនប្រែប្រួលសរុប** | | | | **12,454,000** | | **883,389** |
| ផ្ទះសំណាញ់ (៥ឆ្នាំ) | ម៉ែត្រការ៉េ | 250 | 45,000 | 11,250,000 | 15 | 750,000 |
| ម៉ាស៊ីនបូមទឹក (៥ឆ្នាំ) | គ្រឿង | 1 | 400,000 | 400,000 | 15 | 26,667 |
| ប្រព័ន្ធដំណក់ទឹក (២ឆ្នាំ) | ដុំ | 1 | 80,000 | 80,000 | 6 | 13,333 |
| ទុយោ (៥ឆ្នាំ) | ដើម | 10 | 7,000 | 70,000 | 15 | 4,667 |
| កៅស៊ូគ្របរង (១ឆ្នាំ) | ដុំ | 1 | 80,000 | 80,000 | 3 | 26,667 |
| សំណាញ់ទ្រើង (៣ឆ្នាំ) | ដុំ | 7 | 10,000 | 70,000 | 9 | 7,778 |
| បង្គោលឈើ (២ឆ្នាំ) | ដើម | 170 | 500 | 85,000 | 6 | 14,167 |

| | | | | | | |
|---|---|---|---|---|---|---|
| ខ្សែខ្មៅ (២ឆ្នាំ) | គ.ក | 2 | 7,000 | 14,000 | 6 | 2,333 |
| រោងបណ្ដុះកូន (៣ឆ្នាំ) | រោង | 1 | 100,000 | 100,000 | 9 | 11,111 |
| ថាសបណ្ដុះកូន (២ឆ្នាំ) | ថាស | 5 | 2,000 | 10,000 | 6 | 1,667 |
| សំណាញ់បន្ទយកំដៅ (៥ឆ្នាំ) | ដុំ | 0.5 | 200,000 | 100,000 | 15 | 6,667 |
| កញ្ច្រែងប្រមូលផល (៥ឆ្នាំ) | កញ្ច្រែង | 3 | 25,000 | 75,000 | 15 | 5,000 |
| ធុងបាញ់ថ្នាំ ២០លីត្រ (៣ឆ្នាំ) | ធុង | 1 | 120,000 | 120,000 | 9 | 13,333 |
| **៣-ចំណេញសរុប** | | | | | | **1,935,611** |
| **ថ្លៃដើម/គ.ក** | | | | | | 2,966.13 |
| **ចំណេញ/គ.ក** | | | | | | 3,033.87 |

**៥-លទ្ធភាពចំណេញផ្អែកលើបម្រែបម្រួលទិន្នផល ÷** (ក្នុងផ្ទះសំណាញ់ ២៥០ ម៉ែត្រការ៉េ)

- ទិន្នផលទាបបំផុត ៦៥% ឬ ៥៥៣គ.ក/៥០០ដើម
- ទិន្នផលមធ្យម ៧៥% ឬ ៦៣៨គ.ក/៥០០ដើម
- ទិន្នផលខ្ពស់បំផុត ៨៥% ឬ ៧២៣គ.ក/៥០០ដើម

| ទិន្នផល គ.ក | តម្លៃ រៀល/គ.ក | ចំណូល រៀល | ចំណាយ រៀល | ចំណេញ-ខាត | |
|---|---|---|---|---|---|
| | | | | រៀល | %ធៀបចំណាយ |
| 553 | 6,000 | 3,318,000 | 1,892,389 | 1,425,611 | 75% |
| 638 | 6,000 | 3,828,000 | 1,892,389 | 1,935,611 | 102% |
| 723 | 6,000 | 4,338,000 | 1,892,389 | 2,445,611 | 129% |

**៦-ខ្សែច្រវាក់តម្លៃ÷**



កសិករលក់ ៦,០០០៛/គ.ក - ថ្លៃដើម២,៩៧០៛/គ.ក = ចំណេញ ៣,០៣០៛/គ.ក



ឈ្មួញបោះដុំ ៨,០០០៛/គ.ក (ថ្លៃដឹកជញ្ជូន ៥០០៛/គ.ក) ចំណេញ ១,៥០០៛/គ.ក



អ្នកលក់រាយ ១៥,០០០៛/គ.ក (ជួលតូប និងខូចខាត៣,០០០៛/គ.ក) ចំណេញ ៤,០០០៛/គ.ក

### ៧-ហានិភ័យ ÷

តាមរយៈនៃការចុះសិក្សាផ្ទាល់ពីបទពិសោធន៍លើការដាំដុះត្រសក់ផ្អែមរបស់កសិករនៅស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង ហានិភ័យដែលអាចកើតមានជាយថាហេតុលើដំណើរការដាំដុះដែលនាំឱ្យទិន្នផលមានការធ្លាក់ចុះ គឺបញ្ហាជំងឺផ្សិត បាត់តេរី និងវីរុស ដោយសារទឹកភ្លៀងនៅដើមរដូវវស្សា។ ដើម្បីកាត់បន្ថយ និងគ្រប់គ្រងបញ្ហាខាងលើនេះ កសិករត្រូវមានវិធានការគ្រប់គ្រងកម្រិតទឹកស្រោចស្រពឱ្យបានសមស្រប និងប្រើប្រាស់ថ្នាំការពារជំងឺឱ្យបានទៀតទាត់។

### ៨-សេចក្តីសន្និដ្ឋាន

ត្រសក់ផ្អែមជាដំណាំចំណាយដើមទុនច្រើនក្នុងការដាំដុះ ថែទាំ តម្រូវឱ្យកសិករមានការប្រុងប្រយ័ត្នខ្ពស់លើការគ្រប់គ្រងទឹក ជី សត្វល្អិត និងជំងឺ ហើយបញ្ហាទាំងនេះគឺអាចបំផ្លាញទិន្នផលត្រសក់ផ្អែមដល់ថ្ងៃប្រមូលផលតែម្តង។ ការគ្រប់គ្រងដំណាំត្រសក់ផ្អែមបានល្អ កសិករនឹងមានលទ្ធភាពចំណេញ និងជាផលិតផលដែលមានតម្រូវការទីផ្សារច្រើន ឬមានក្រុមហ៊ុនចុះកុងត្រាទទួលទិញលក់បន្តទៅផ្សារទំនើបផ្សេងៗ។

---

**ប្រភពនៃការសិក្សាស្រាវជ្រាវ ÷**

-កសិករដាំដំណាំត្រសក់ផ្អែម ស្រុករតនមណ្ឌល ខេត្តបាត់ដំបង

-ឯកសារបច្ចេកទេសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ